GMAC

Garment Manufacturers Association in Cambodia

# សេចក្តីថ្លែងការណ៍
# ស្តីពីការចរចាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១

កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ កន្លងមកនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងមួយ ស្តីពីកាលវិភាគនៃការចរចាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២១ ដែលគ្រោងនឹងចាប់ផ្តើមពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២០។

ស្ថិតនៅក្នុងកាលៈទេសៈបច្ចុប្បន្នដែលប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសនៅលើពិភពលោក បាននិងកំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការរីករាលដាលជាសកលនៃជម្ងឺផ្លូវដង្ហើមថ្មី កូវីដ១៩ (Covid-19) បណ្តាលឲ្យវិស័យមួយចំនួនជួបវិបត្តិជាច្រើនដែលមិនអាចប៉ាន់ស្មានបានជាមុន។ ជាក់ស្តែងនៅក្នុងផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង រោងចក្រ សហគ្រាសជាច្រើនបានផ្អាកដំណើរការសកម្មភាពផលិតកម្មជាបណ្តោះអាសន្ន ខណៈមួយចំនួនទៀតបានសម្រេចចិត្តឈប់ដំណើរការសកម្មភាពជាស្ថាពរតែម្តង ពីព្រោះអ្នកបញ្ជាទិញជាច្រើនបានលុបចោលការបញ្ជាទិញ និងបដិសេធមិនទទួលយកទំនិញដែលបានផលិតរួច ក៏ដូចជាមិនបានធ្វើការទូទាត់ប្រាក់ដែលបានព្រមព្រៀងសម្រាប់ទំនិញដែលបានផលិត និងទទួលយករួច ដោយហេតុថានៅតាមបណ្តាហាងលក់ទំនិញជុំ និងរាយនៅជុំវិញពិភពលោកបានបិទស្ទើរតែអស់ ខណៈតម្រូវការនៅក្នុងសកលលោកមានការធ្លាក់ចុះដល់កម្រិតអប្បបរមា។

កថាខណ្ឌទី៣ នៃមាត្រា១០៧ នៃច្បាប់ស្តីពីការងារ និងមាត្រា៥ នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា បានកំណត់ថា ការចរចាប្រាក់ឈ្នួលអប្បបរមាតម្រូវឲ្យផ្តោតលើធាតុផ្សំ ២ (ពីរ) គឺ លក្ខណៈវិនិច្ឆ័យបែបសង្គម និងលក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ច។ នៅក្នុងនោះ ការពិចារណាទៅលើកម្រិតចំណេញរបស់វិស័យ គឺជាកត្តាចម្បងមួយក្នុងចំណោមកត្តាចម្បងទាំង៧ (ប្រាំពីរ) នៃលក្ខណៈវិនិច្ឆ័យទាំងពីរនេះ។ បន្ថែមពីនេះ កថាខណ្ឌទី២ នៃមាត្រា១១ នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា បានកំណត់ថា "*ក្នុងករណីប្រធានសក្តិ ឬករណីចាំបាច់ណាមួយ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចចេញប្រកាសផ្អាក ឬកែសម្រួលកាលវិភាគនៃការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាបាន។ ក្នុងករណីនេះ ប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ចុងក្រោយនឹងមានសុពលភាពអនុវត្តបន្តរហូតមានការកំណត់ប្រាក់ឈ្នួលអប្បបរមាថ្មីមកជំនួស។*"

ស្ថិតក្នុងកាលៈទេសៈនេះ វិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងកំពុងមានភាពផុយស្រួយ និងមានភាពមិនច្បាស់លាស់ក្នុងការវិលត្រឡប់មករកសភាពដើមវិញ ក៏ដូចជាការធ្វើឲ្យប្រសើរឡើងវិញរបស់វិស័យនេះនឹងត្រូវចំណាយពេលយូរ។ ម្យ៉ាងវិញទៀត ក្នុងពេលបច្ចុប្បន្ន រោងចក្រយ៉ាងច្រើននៅក្នុងវិស័យនេះបាននិងកំពុងព្យួរការងារ និងមានរោងចក្រចំនួនមួយចំនួនកំពុងបិទទ្វារ ដូចនេះយន្តការគាំទ្រនានាគឺជាវិធានការចាំបាច់ដើម្បីជួយរក្សាលំនឹងនៃវិស័យនេះ។ ដូចនេះ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) យល់ឃើញថា ការចរចាប្រាក់ឈ្នួលអប្បបរមាថ្មីសម្រាប់ឆ្នាំ២០២១ខាងមុខនេះ គួរត្រូវបានពន្យារពេល។ ប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០២០ គួរបន្តសុពលភាពអនុវត្តរហូតដល់វិស័យនេះ អាចត្រឡប់ទៅរកសភាពដើមវិញ។



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantouk, Khan Por Sen Chey, Phnom Penh, Cambodia.
Tel: (855) 23-301 181 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org

សមាគមសង្ឃឹមយ៉ាងមុតមាំថា ការចរចាប្រាក់ឈ្នួលអប្បបរមាថ្មីសម្រាប់ឆ្នាំ២០២១នេះនឹងត្រូវផ្អាកជាបណ្ដោះអាសន្នរហូតដល់ស្ថានភាពនៃវិស័យនេះមានភាពប្រក្រតីឡើងវិញ។ ការបង្អង់ការចរចាប្រាក់ឈ្នួលអប្បបរមានឹងជាយន្តការមួយ ក្នុងការគាំទ្រឱ្យវិស័យនេះនៅបន្តមានជីវិតរស់នៅ ក៏ដូចជាការរក្សាការងារសម្រាប់បងប្អូនកម្មករនិយោជិតយ៉ាងដូច្នេះដែរ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០

**សមាគមរោងចក្រកាត់ដេរនៅកម្ពុជា**